ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ០៣ សរ

# សារាចរ
# ស្តីពី
# ការអនុវត្តយន្តការរបាយការណ៍សិទ្ធិមនុស្សនៅកម្ពុជាសម្រាប់អង្គការសហប្រជាជាតិ

ក្នុងនាមរដ្ឋជាសមាជិកនៃអង្គការសហប្រជាជាតិ ព្រះរាជាណាចក្រកម្ពុជាបានចូលជាសមាជិកនៃសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្សចំនួន៨ ក្នុងចំណោមសន្ធិសញ្ញានិងអនុសញ្ញាអន្តរជាតិទាំងអស់ចំនួន៩ ដែលធ្វើឱ្យកម្ពុជាជាប្រទេសឈានមុខគេក្នុងតំបន់ ក្នុងការទទួលយកលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិយកមកអនុវត្ត។ រាជរដ្ឋាភិបាលដែលមានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាជាសេនាធិការបានបង្ហាញឆន្ទៈខ្ពស់ក្នុងការលើកស្ទួយសិទ្ធិមនុស្សនៅកម្ពុជា និងបានចូលរួមគ្រប់យន្តការអន្តរជាតិស្តីពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ មានជាអាទិ៍ យន្តការនៃការសរសេររបាយការណ៍សិទ្ធិមនុស្ស និងចូលរួមការពាររបាយការណ៍សិទ្ធិមនុស្សនៅអង្គការសហប្រជាជាតិ។

ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តយន្តការរបាយការណ៍សិទ្ធិមនុស្សនៅកម្ពុជាសម្រាប់អង្គការសហប្រជាជាតិដែលជាកាតព្វកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាលដាក់ចេញវិធានការដូចខាងក្រោម៖

១- ដោយការងារសិទ្ធិមនុស្សជាការងារអន្តរវិស័យ គ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត និងអង្គភាពជំនាញគ្រប់ជាន់ថ្នាក់ ត្រូវសហការឱ្យបានជិតស្និទ្ធប្រកបដោយការទទួលខុសត្រូវខ្ពស់ ជាមួយគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ក្នុងរាល់ការងារការពារនិងលើកស្ទួយសិទ្ធិមនុស្សនៅកម្ពុជា មានជាអាទិ៍ ការងារស្រាវជ្រាវ អប់រំ និងផ្សព្វផ្សាយអំពីសិទ្ធិមនុស្ស ការងារទទួលនិងដោះស្រាយពាក្យបណ្តឹង និងការងារស៊ើបអង្កេតនិងត្រួតពិនិត្យស្ថានភាពសិទ្ធិមនុស្សនៅតាមពន្ធនាគារនិងកន្លែងឃាត់ខ្លួននិងឃុំខ្លួនផ្សេងៗទៀត។

២- គ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត និងអង្គភាពជំនាញគ្រប់ជាន់ថ្នាក់ ត្រូវធ្វើការសហការឱ្យបានពេញលេញនិងប្រកបដោយការទទួលខុសត្រូវខ្ពស់ ជាមួយគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាក្នុងដំណើរការរៀបចំរបាយការណ៍សិទ្ធិមនុស្សនៅកម្ពុជាសម្រាប់អង្គការសហប្រជាជាតិ មានជាអាទិ៍ ការផ្តល់ព័ត៌មាននិងទិន្នន័យ ការចូលរួមកិច្ចប្រជុំ និងការផ្តល់របាយការណ៍ឆ្លើយតបឱ្យបានទៀងទាត់តាមកាលកំណត់។

៣- គ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត និងអង្គភាពជំនាញគ្រប់ជាន់ថ្នាក់ ត្រូវសហការជាមួយគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ផ្តល់ការឆ្លើយតបប្រកបដោយប្រសិទ្ធភាពនិងទាន់ពេលវេលាទៅនឹងរបាយការណ៍ទាំងឡាយពាក់ព័ន្ធទៅនឹងស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាដែលបានដាក់ជូនទៅអង្គការសហប្រជាជាតិដោយការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សប្រចាំនៅកម្ពុជា របាយការណ៍របស់អ្នករាយការណ៍ពិសេសនានារបស់អង្គការសហប្រជាជាតិស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា និងរបាយការណ៍សិទ្ធិមនុស្សនៅកម្ពុជាដទៃទៀតដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ខ្លួន។

៤- ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវសហការរៀបចំបញ្ជូនតំណាងចូលរួមជាមួយគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ដើម្បីទៅការពាររបាយការណ៍សិទ្ធិមនុស្សតាមសន្ធិសញ្ញានីមួយៗនៅអង្គការសហប្រជាជាតិ តាមការស្នើសុំរបស់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា។

៥- តាមសំណើរបស់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ទីស្តីការគណៈរដ្ឋមន្ត្រីស្នើសុំថវិកាក្នុងកញ្ចប់ថវិកាពិសេសរបស់រាជរដ្ឋាភិបាលក្នុងការបញ្ជូនប្រតិភូតំណាងនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីទៅការពាររបាយការណ៍សិទ្ធិមនុស្សកម្ពុជានៅអង្គការសហប្រជាជាតិ សម្រាប់ប្រតិភូនៃគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា និងប្រតិភូតំណាងក្រសួង ស្ថាប័នដែលចាំបាច់។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័ន គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា និងរដ្ឋបាលរាជធានី ខេត្ត ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពនិងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃ ៣ុឆ ៤ ១៣៦ ខែ មាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**អន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- រដ្ឋបាលរាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ